ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខៈ ១

ឆ្នាំ២០០៩

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ការិយបរិច្ឆេទ ២០០៦

# អារម្ភកថា

ប្រទេសកម្ពុជាទទួលបានសុខសន្តិភាព និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយសារការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការបង្រួបបង្រួមជាតិ និងការដាក់ចេញនូវកម្មវិធីកំណែទំរង់នានាលើគ្រប់វិស័យ ពិសេសការកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរដ្ឋបាល ដើម្បីឈានទៅសំរេច នូវគោលនយោបាយអភិបាលកិច្ចល្អ ការអភិវឌ្ឍន៍ប្រកបដោយចិរភាព សមធម៌ និងការកាត់បន្ថយភាពក្រីក្រ ។

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសវនកម្មកំពូល និងមានភាពឯករាជ្យអំពីកិច្ចប្រតិបត្តិការការងារ ត្រូវបានបង្កើតឡើងនៅខែមីនា ឆ្នាំ២០០០។ ការបង្កើតនូវស្ថាប័នកំពូលនេះ ស្តែងចេញពីឆន្ទៈ និងការប្តេជ្ញាដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា ក្នុងគោលបំណងដើម្បីអនុវត្តការងារត្រួតពិនិត្យ វាយតំលៃ និងធ្វើរបាយការណ៍ជាប្រចាំស្តីពីលទ្ធផលការងារដែលសំរេចបាន និងលើកអនុសាសន៍កែលំអលើចំណុចខ្វះខាតនានារបស់ក្រសួង-ស្ថាប័ន ព្រមទាំងអង្គភាពពាក់ព័ន្ធទាំងឡាយ ផ្ញើជូនទៅរដ្ឋសភា ព្រឹទ្ធសភា និងជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន សំដៅធ្វើអោយមានភាពកាន់តែប្រសើរនូវអភិបាលកិច្ចល្អ និងការអភិវឌ្ឍន៍ ។

សមិទ្ធផលទាំងឡាយដែលកើតចេញពីឆន្ទៈដ៏មោះមុត និងការខិតខំប្រឹងប្រែងអនុវត្តតួនាទីយ៉ាងខ្ជាប់ខ្ជួនរបស់មន្ត្រីសវនកម្មទាំងអស់ បានជំរុញអោយអាជ្ញាធរសវនកម្មជាតិមានការអភិវឌ្ឍន៍ និងមានលទ្ធភាពធ្វើការផ្សព្វផ្សាយរបាយការណ៍ជាសាធារណៈ ស្របតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ។ របាយការណ៍នេះ រួមមានបញ្ចូលនូវលទ្ធផល និងការវាយតំលៃលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រសួង-ស្ថាប័ន រដ្ឋបាលខេត្ត-ក្រុង រដ្ឋបាលមូលដ្ឋាន ការធ្វើសវនកម្មលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦ និងការផ្តល់អនុសាសន៍កែលំអនូវរាល់ចំណុចខ្វះខាតនានា ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណដ៏ខ្ពង់ខ្ពស់ចំពោះរាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា ដែលជានិច្ចកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិ ទាំងក្នុងក្របខ័ណ្ឌច្បាប់ ក៏ដូចជាក្របខ័ណ្ឌហិរញ្ញវត្ថុ សំភារៈ និងស្មារតី។ ជាមួយគ្នានេះដែរ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការកិច្ចសហប្រតិបត្តិការបច្ចេកទេសរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (GTZ) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (WB) ប្រទេសដាណឺម៉ាក (DANIDA) ព្រមទាំងស្ថាប័នសវនកម្មកំពូលនានា ដែលបានផ្តល់ការគាំទ្រ និងជួយឧបត្ថម្ភផ្សេងៗក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ការងារ និងសូមអរគុណជាអនេកប្បការដល់មន្ត្រីនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចដ៏ឧត្តុង្គឧត្តមធ្វើអោយសំរេចបាននូវស្នាដៃជូនជាតិមាតុភូមិនៃយើង ។

រាជធានីភ្នំពេញ,ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩

**អគ្គសវនករ**

**អ៊ុត ឈន**

# មាតិកា


ទំព័រ

**១. សេចក្តីសង្ខេប** ០១

**២. សេចក្តីផ្តើម** ០៣

**២.១. លក្ខណៈទូទៅ** ០៣

**២.២. ការអនុវត្តន៍ និងដែនកំណត់សវនកម្ម** ០៣

**២.៣. គោលបំណងនៃការផ្សព្វផ្សាយ** ០៤

**៣. ការគ្រប់គ្រងថវិកា** ០៥

**៣.១. នីតិវិធីនៃកិច្ចដំណើរការថវិកា** ០៥

**៣.២. កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកា** ០៦

**៤. លទ្ធផលសវនកម្មក្នុងការិយបរិច្ឆេទ ២០០៦** ០៦

**៤.១. ការគ្រប់គ្រងចំណូលថវិកា** ០៦

៤.១.១. ការត្រួតពិនិត្យទំនិញតាមមាត់ច្រកនាំចូលដើមទី ០៦

៤.១.២. វិក្កយបត្រ និងបញ្ជីវេចខ្ចប់ទំនិញនាំចូល ០៧

៤.១.៣. ការគ្រប់គ្រងឃ្លាំងទំនិញនៅប៉ោយប៉ែត ០៨

៤.១.៤. កិច្ចសហការការងាររវាងនាយកដ្ឋានពន្ធដារ និងទីចាត់ការគយ និងរដ្ឋាករ ០៩

៤.១.៥. ការគ្រប់គ្រងការប្រកាសពន្ធ ១០

៤.១.៦. ការចុះអាជីវកម្មដ្ឋានតាមរបបម៉ៅការក្នុងបញ្ជីអនុម័តពន្ធ ១១

៤.១.៧. ការប្រមូលពន្ធប្រថាប់ត្រា ១១

៤.១.៨. ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ១២

៤.១.៩. ការបង្កើតបញ្ជីដីមិនបានប្រើប្រាស់ ១២

៤.១.១០. ការកំណត់ថ្លៃឈ្នួលដីសម្បទាន ១៣

៤.១.១១. ការផ្ទេរថវិកាវិភាជន៍ជូនឃុំ ១៤

**៤.២. ការគ្រប់គ្រងចំណាយថវិកា** ១៥

៤.២.១. ការបើកផ្តល់ប្រាក់មុនកាលកំណត់នៃកិច្ចសន្យា ១៥

៤.២.២. ការចូលរួមរបស់គណៈកម្មការលទ្ធកម្មឃុំ ១៦

៤.២.៣. ការដកប្រាក់រង្វាន់សំរាប់ការលើកទឹកចិត្ត ១៧

៤.២.៤. រយៈពេលកំណត់ក្នុងការទទួល និងទូទាត់អាណត្តិបើកប្រាក់ ១៧

**៤.៣. ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ** ១៨

ការធ្វើបណ្ណសំគាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ ១៨

**៤.៤. កិច្ចបញ្ជីកាគណនេយ្យ** ១៩

៤.៤.១. ការគ្រប់គ្រងហិរញ្ញប្បទានក្រៅរតនាគារជាតិ ១៩

៤.៤.២. កិច្ចបញ្ជីកាបំណុលមិនទាន់ប្រមូលផ្ដុំ ២០

**៥. សេចក្ដីសន្និដ្ឋាន** ២១

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០០៦

## ១. សេចក្តីសង្ខេប

អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ អាជ្ញាធរ-សវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។ ចំពោះការិយបរិច្ឆេទ២០០៦ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្តាក្រសួង-ស្ថាប័ន រដ្ឋបាលខេត្ត-ក្រុង រដ្ឋបាលមូលដ្ឋាន និងសហគ្រាស-សាធារណៈ មួយចំនួន ជាពិសេស ធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦ ដែលមានលទ្ធផលសង្ខេបដូចខាងក្រោម ÷

ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានស្ថេរភាពល្អ ដែលកំណើនសេដ្ឋកិច្ចសំរេចបាន ១០,៨% គឺខ្ពស់ជាងការគ្រោងទុក ដែលមាន ៦,១%។ លទ្ធផលនេះ បានមកដោយសារការអនុវត្តន៍បានយ៉ាងត្រឹមត្រូវនូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិលើកទីពីរ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ជាពិសេស ការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ និងការអនុវត្តន៍កម្មវិធីកែទំរង់លើគ្រប់វិស័យ ដូចជា ការអនុវត្តន៍កម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍន៍វិស័យឯកជន ...។

ការអនុវត្តន៍ចំណូលតាមរយៈរតនាគារជាតិក្នុងឆ្នាំសំរេចបាន ៣.៣៩៧.០១០ លានរៀល ស្មើនឹង ១១៥%នៃផែនការឆ្នាំដែលមាន ២.៩៥៦.៣២៥ លានរៀល។ ទន្ទឹមនឹងលទ្ធផលដែលសំរេចបាននេះ បើផ្អែកលើការសង្កេតជាទូទៅនៅមានកំរិតនៅឡើយ គឺដោយសារកត្តាមួយចំនួនដូចជា ការទប់ស្កាត់ និងការបង្ក្រាបអំពើរត់ពន្ធនៅតាមមាត់ច្រកនាំចូលដើមទីពុំទាន់ត្រូវបានធ្វើឡើងប្រកបដោយប្រសិទ្ធភាពពេញលេញ ឯកសារទំនិញនាំចូលមួយចំនួនពុំអាចបញ្ជាក់បាននូវភាពជាក់ស្តែងនៃទំនិញ ឃ្លាំងស្តុកទំនិញនៅប៉ោយប៉ែតពុំត្រូវបានស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យច្បាស់លាស់ដោយរដ្ឋបាលគយ និងរដ្ឋាករ កង្វះកិច្ចសហការល្អរវាងនាយកដ្ឋានពន្ធដារ និងទីចាត់ការគយ និងរដ្ឋាករក្នុងការត្រួតពិនិត្យលើការប្រើប្រាស់លេខអត្តសញ្ញាណកម្មអាករលើតំលៃបន្ថែម(អតប)។ ការត្រួតពិនិត្យកំហុសលើការប្រកាសពន្ធរបស់ក្រុមហ៊ុន-សហគ្រាសមិនបានទាន់ពេលវេលា ការចុះអាជីវកម្មដ្ឋានក្នុងបញ្ជីអនុម័តពន្ធមិនទាន់បានគ្រប់ចំនួន ការប្រមូលពន្ធប្រថាប់ត្រាលើការផ្គត់ផ្គង់ទំនិញ ឬសេវាជូនអង្គភាពរដ្ឋមិនទាន់បានត្រឹមត្រូវ ការពុំទាន់បានកំណត់ថ្លៃឈ្នួលដីសម្បទានសំរាប់រយៈពេលវែង ការបន្សល់ទុកនូវបំណុលត្រូវទារមួយចំនួន ។

ការអនុវត្តន៍ចំណាយតាមរយៈរតនាគារជាតិក្នុងឆ្នាំសំរេចបាន ២.៨១៣.០៤៦ លានរៀល គឺស្មើនឹង ៩៥% នៃផែនការដែលមាន ២.៩៥៦.៣២៥ លានរៀល។ ក្នុងការអនុវត្តន៍ចំណាយនេះ មានចំណុចគួរអោយកត់សំគាល់មួយចំនួនដូចជា ការបើកផ្តល់ប្រាក់មុនកាលកំណត់នៃកិច្ចសន្យាដែលនាំអោយការអនុវត្តន៍កិច្ចសន្យាពុំបានពេញលេញ ការបញ្ជូនអាណត្តិបើកប្រាក់យ៉ាងគំហុកនៅចុងឆ្នាំ និងនៅក្រោយថ្ងៃឱសានវាទបិទបញ្ជីបង្កអោយមានការកកស្ទះអាណត្តិនៅរតនាគារជាតិជារៀងរាល់ឆ្នាំ ។

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រព្រឹត្តិទៅពុំទាន់គ្រប់ជ្រុងជ្រោយ ដូចជា ទ្រព្យសម្បត្តិរដ្ឋមួយចំនួនត្រូវបានរំលោភកាន់កាប់ដោយឯកជន ការធ្វើបញ្ជីសារពើភ័ណ្ឌ និងប័ណ្ណសំគាល់កម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋមិនបានគ្រប់ចំនួន និងទាន់ពេលវេលា ...។

ការកត់ត្រាតាមដានហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ អំពីកម្ចីធនាគារពិភពលោក និងអំណោយបរទេស មិនទាន់មានលក្ខណៈពេញលេញនៅឡើយ។ កិច្ចបញ្ជីកាបំណុលមិនត្រូវបានធ្វើការកត់ត្រាតាមដានជាលក្ខណៈប្រមូលផ្តុំនៅរតនាគារជាតិនោះទេ ដែលនាំអោយមានការលំបាកក្នុងការតាមដាន និងត្រួតពិនិត្យ ។

## ២. សេចក្តីផ្តើម

### ២.១ លក្ខណៈទូទៅ

អាជ្ញាធរសវនកម្មជាតិ ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ ច្បាប់នេះមានគោលបំណងបង្កើតនូវអាជ្ញាធរសវនកម្មជាតិមួយ ដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចអនុវត្តការងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល រួមមាន ការធ្វើសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យគណនី ប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាស្ថាប័នគ្រប់គ្រង។ ក្នុងស្មារតីនេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្មលើបណ្តាក្រសួង-ស្ថាប័ន ភ្នាក់ងារ អាជ្ញាធរ ធនាគារជាតិ ស្ថាប័ន-ហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុរដ្ឋចំរុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលខេត្ត-ក្រុង រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជនផង ។

ទន្ទឹមនឹងនេះ អាជ្ញាធរសវនកម្មជាតិមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ ហើយត្រូវធ្វើរបាយការណ៍ផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងជូនទៅរាជរដ្ឋាភិបាលដើម្បីជ្រាបជាព័ត៌មាន ។

### ២.២ ការអនុវត្តន៍ និងដែនកំណត់សវនកម្ម

អាជ្ញាធរសវនកម្មជាតិ ធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មរបស់អង្គការអន្តរជាតិ នៃស្ថាប័នសវនកម្មកំពូល " INTOSAI Audit Standards" និងស្តង់ដារនៃការធ្វើសវនកម្មទូទៅ។ ស្តង់ដារសវនកម្មទាំងនេះ តំរូវអោយអាជ្ញាធរសវនកម្មជាតិរៀបចំផែនការ និងអនុវត្តការងារសវនកម្ម ដោយផ្អែកលើមូលដ្ឋាននៃការពិនិត្យវាយតំលៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងការធ្វើតេស្តលើឯកសារ ដើម្បីទទួលបាននូវភស្តុតាងនៃចំណុចខ្វះខាត និងផ្តល់អនុសាសន៍កែលំអ ។

ចាប់តាំងពីអាជ្ញាធរសវនកម្មជាតិបានដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតមកដល់ឆ្នាំ២០០៩ នេះ អាជ្ញាធរសវនកម្មជាតិបានខិតខំបំពេញតួនាទី និងភារកិច្ចយ៉ាងខ្ជាប់ខ្ជួនក្នុងការធ្វើសវនកម្មលើបណ្តាក្រសួង-ស្ថាប័ន រដ្ឋបាលខេត្ត-ក្រុង រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ និងគំរោងផ្សេងៗសរុបមានចំនួន ៤៥៩ របាយការណ៍ពិសេស គឺធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។ ដោយឡែក សំរាប់ការិយបរិច្ឆេទ ២០០៦ មានបញ្ហាគួរអោយកត់សំគាល់ដូចបានដកស្រង់ និងលើកឡើងក្នុងចំណុច ៤ នៃរបាយការណ៍នេះ ស្របតាមមាត្រា ២៩ និងមាត្រា ៣៧ នៃច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា ។

## ២.៣ គោលបំណងនៃការផ្សព្វផ្សាយ

ចាប់តាំងពីការធ្វើសវនកម្មរហូតមកដល់ពេលនៃការផ្សព្វផ្សាយនេះ អង្គភាពរងសវនកម្មនានាដែលមានកង្វះខាតលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានខិតខំអនុវត្តកែលំអតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិគួរជាទីមោទនៈ មានជាអាទិ៍ ការលុបបំបាត់ជាបន្តបន្ទាប់នូវរបបគយនាំចូលដើម្បីនាំចេញដែលគ្រប់គ្រងមិនបាន ការផ្លាស់ប្តូរពីការបង់ពន្ធជាសាច់ប្រាក់នៅនឹងកន្លែងមកការបង់ពន្ធតាមរយៈធនាគារ ឬរតនាគារដើម្បីកាត់បន្ថយហានិភ័យក្នុងការគ្រប់គ្រងសាច់ប្រាក់ ការផ្លាស់ប្តូរលេខអត្តសញ្ញាណកម្មសារពើពន្ធថ្មីដើម្បីគ្រប់គ្រងសកម្មភាពអាជីវកម្មក្រុមហ៊ុន-សហគ្រាសអោយមានប្រសិទ្ធភាព ការណែនាំជំរុញអោយមានការបង់ពន្ធប្រថាប់ត្រាលើគ្រប់កិច្ចសន្យាផ្គត់ផ្គង់ទំនិញជូនរដ្ឋ ការចេញសេចក្តីជូនដំណឹង និងលិខិតបទដ្ឋានផ្សេងៗស្តីពីការទារបំណុលសារពើពន្ធ និងមិនមែនសារពើពន្ធជាច្រើនករណី។ ការធ្វើអោយមានភាពប្រសើរក្នុងការបើកផ្តល់សាច់ប្រាក់ និងការពង្រឹងកិច្ចលទ្ធកម្មសាធារណៈ ការណែនាំជំរុញអោយធ្វើបញ្ជីសារពើភ័ណ្ឌ និងប័ណ្ណសំគាល់កម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ។ ការផ្លាស់ប្តូរកិច្ចបញ្ជីកាគណនេយ្យពីការប្រើប្រាស់មូលដ្ឋានសាច់ប្រាក់ផង និងបង្គរផង មកប្រើប្រាស់តែមូលដ្ឋានបង្គរ និងការកាន់បញ្ជីកាបំណុលប្រមូលផ្តុំនៅរតនាគារជាតិ...។ ប៉ុន្តែជាមួយគ្នានេះដែរ ក៏នៅមានអង្គភាពរងសវនកម្មមួយចំនួនពុំទាន់បានយកចិត្តទុកដាក់អនុវត្តកែលំអអោយបានទាន់ពេលវេលានៅឡើយ ។

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ មានគោលបំណងរួមចំណែកជួយដល់ស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងារ តាមរយៈការចង្អុលបង្ហាញចំណុចខ្វះខាតផ្សេងៗដែលបានអនុវត្តក្នុងពេលកន្លងមក និងផ្តល់អនុសាសន៍កែលំអសំរាប់ពេលអនាគត សំដៅធ្វើអោយការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានភាពកាន់តែប្រសើរ ។

នេះជាលើកទីមួយហើយ ដែលអាជ្ញាធរសវនកម្មជាតិបានរៀបចំរបាយការណ៍សវនកម្មផ្សព្វផ្សាយជាសាធារណៈ។ អាជ្ញាធរសវនកម្មជាតិមានការសោកស្តាយចំពោះភាពយឺតយ៉ាវក្នុងការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈនាបណ្តាឆ្នាំកន្លងមក ដោយសារកង្វះខាតធនធានបច្ចេកទេស និងបទពិសោធន៍ការងារ ។ ទន្ទឹមនឹងនេះ អាជ្ញាធរសវនកម្មជាតិមានសេចក្តីសោមនស្សរីករាយទទួលយកនូវការជួយជាមតិស្ថាបនាពីគ្រប់មជ្ឈដ្ឋាន ។

អាជ្ញាធរសវនកម្មជាតិអនុវត្តកាតព្វកិច្ចផ្សព្វផ្សាយរបាយការណ៍ជាសាធារណៈ ស្របតាមមាត្រា២៩ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថា " របាយការណ៍ដែលធ្វើដោយអគ្គសវនករ ត្រូវបានចាត់ទុកជាឯកសារសាធារណៈ "។ អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង-ស្ថាប័ន ខេត្ត-ក្រុង ក្រុមហ៊ុន-សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងពេលដែលមានតតីយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈ ទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅជាយថាហេតុ ។

## ៣. ការគ្រប់គ្រងថវិកា

### ៣.១ នីតិវិធីនៃកិច្ចដំណើរការថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០០៦នេះ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលជាអាទិ៍មានដូចតទៅ ÷

- ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦ ត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៥ សំរាប់អោយរាជរដ្ឋាភិបាលប្រតិបត្តិ និងមានលទ្ធភាពប្រើប្រាស់ថវិកាក្នុងកិច្ចដំណើរការការងារ និងការអភិវឌ្ឍន៍ប្រទេសលើគ្រប់វិស័យ ។

- អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រង់មាត្រា ២ បានបញ្ជាក់ថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានតួនាទី និងភារកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ដោយត្រូវធ្វើឡើងតាមរយៈនៃការរៀបចំ និងអនុវត្តអោយបានត្រឹមត្រូវនូវគោលនយោបាយក្របខ័ណ្ឌច្បាប់ និងបទបញ្ញាទាំងឡាយ ដែលទាក់ទងនឹងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ ទ្រព្យសម្បត្តិរដ្ឋ កិច្ចការវិនិយោគ និង ឧស្សាហកម្មហិរញ្ញវត្ថុ ព្រមទាំងច្បាប់ និងបទបញ្ញាផ្សេងៗទៀត...។

- អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យ-សាធារណៈ ត្រង់មាត្រា ១១៦ បានបញ្ជាក់ថា សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋត្រូវបានដាក់ជូនសភាជាតិមុនដំណាច់ឆ្នាំ។ សេចក្តីព្រាងច្បាប់នេះ ផ្អែកលើគណនីទូទៅនៃការគ្រប់គ្រងរដ្ឋបាលហិរញ្ញវត្ថុ និងលើរបាយការណ៍គ្រប់គ្រងទាំងឡាយដែលរៀបចំដោយក្រសួង-ស្ថាប័ន ខេត្ត-ក្រុង នានា ... ។

- ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ២២ បានចែងថា "រាជរដ្ឋាភិបាលត្រូវបញ្ជូនឯកសារនៃការទូទាត់ថវិកាប្រចាំឆ្នាំនីមួយៗ ទៅរដ្ឋសភា ព្រឹទ្ធសភា ដើម្បីពិនិត្យ និងអនុម័ត ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏ត្រូវបញ្ជូនឯកសារនេះទៅអាជ្ញាធរសវនកម្មជាតិដើម្បីធ្វើសវនកម្មដែរ" ។

- សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦ ត្រូវបានរាជរដ្ឋា-ភិបាលបញ្ជូនមកដល់អាជ្ញាធរសវនកម្មជាតិនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៧ សំរាប់ធ្វើសវនកម្ម និងធ្វើសេចក្តីបញ្ជាក់លើសេចក្តីព្រាងច្បាប់នេះ ។

- របាយការណ៍សវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦ ត្រូវបានអាជ្ញាធរសវនកម្មជាតិផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ដើម្បីជូនជ្រាបជារបាយការណ៍ និងជូនជ្រាបជាព័ត៌មាន ។

- ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ២០០៦ ត្រូវបានរដ្ឋសភាអនុម័តនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៨ ។

### ៣.២ កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកា

កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកាឆ្នាំ២០០៦ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តន៍ចំណូល-ចំណាយតាមរយៈរតនាគារជាតិ និងលទ្ធផលនៃការអនុវត្តន៍គំរោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ÷

*ឯកតា : លានរៀល*

| កិច្ចប្រតិបត្តិការថវិកា | ២០០៥ | ២០០៦ | | |
|---|---|---|---|---|
| | អនុវត្ត | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | 1 | 2 | 3 | 4 = (3/2) |
| **I. ចំណូល** | **3.879.562** | **3.814.125** | **4.728.052** | **124%** |
| - ចំណូលចរន្ត | 2.745.005 | 2.740.720 | 2.881.720 | 105% |
| - ចំណូលមូលធន | 271.256 | 215.605 | 515.290 | 239% |
| - ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស | 1.134.557 | 857.800 | 1.331.042 | 155% |
| **II. ចំណាយ** | **2.379.307** | **3.814.125** | **4.144.089** | **109%** |
| - ចំណាយចរន្ត | 1.967.455 | 2.414.255 | 2.366.553 | 98% |
| - ចំណាយមូលធន | 411.852 | 542.070 | 446.494 | 82% |
| - ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស | 1.134.557 | 857.800 | 1.331.042 | 155% |

- ចំណូលសរុបក្នុងឆ្នាំសំរេចបាន ៤.៧២៨.០៥២ លានរៀល ស្មើនឹង១២៤% នៃផែនការដែលមាន ៣.៨១៤.១២៥ លានរៀល ។

- ចំណាយសរុបក្នុងឆ្នាំសំរេចបាន ៤.១៤៤.០៨៩ លានរៀល ស្មើនឹង ១០៩% នៃផែនការដែលមាន ៣.៨១៤.១២៥ លានរៀល ក្នុងនោះចំណាយចរន្តសំរេចបាន ២.៣៦៦.៥៥៣ លានរៀល ស្មើនឹង ៩៨% នៃផែនការដែលមាន ២.៤១៤.២៥៥ លានរៀល និងចំណាយមូលធនសំរេចបាន ៤៤៦.៤៩៤ លានរៀល ស្មើនឹង ៨២% នៃផែនការដែលមាន ៥៤២.០៧០ លានរៀល ។

- ចំណែកចំណូល-ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស ដែលអនុវត្តក្រៅរតនាគារជាតិ ត្រូវបានគ្រោងទុកដោយមានតុល្យភាពចំណូល ស្មើនឹងចំណាយ។ ចំណូល-ចំណាយនេះសំរេចបាន ១.៣៣១.០៤២ លានរៀល ស្មើនឹង ១៥៥% នៃផែនការដែលមាន ៨៥៧.៨០០ លានរៀល ។

## ៤. លទ្ធផលសវនកម្មក្នុងការិយបរិច្ឆេទ ២០០៦

### ៤.១ ការគ្រប់គ្រងចំណូលថវិកា

#### ៤.១.១ ការត្រួតពិនិត្យទំនិញតាមមាត់ច្រកនាំចូលដើមទី

ករណីទំនិញរត់ពន្ធក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន នៅតែជាបញ្ហាមួយគួរអោយចាប់អារម្មណ៍។ ទំនិញជាច្រើនបានហូរចូលមកដល់ក្នុងប្រទេស ឬធ្លាក់ដល់ដៃអ្នកប្រើប្រាស់រួចហើយ ទើបមានការបង្ក្រាប ឬចាប់បង្ខំអោយបង់ពន្ធអាករផ្សេងៗជាក្រោយ។ ជាអាទិ៍ក្នុងឆ្នាំ២០០៦នេះ ករណីដែលរដ្ឋបាលគយបង្ក្រាបបានក្នុងស្រុក

ឬនៅរាជធានីភ្នំពេញ មានចំនួន ៥៥,៦០% នៃបទល្មើសបង្ក្រាបបាននៅទូទាំងប្រទេស (នៅមាត់ច្រកនាំចូលដើមទី និងនៅរាជធានីភ្នំពេញ) ។ ក្រៅពីនេះ នៅមានរថយន្ត និងម៉ូតូជាច្រើនពាន់គ្រឿងទៀត ដែលត្រូវបានម្ចាស់ចូលខ្លួនមកសុំបង់ពន្ធក្រោយពីការនាំចូល ឬបានប្រើប្រាស់រួចហើយ ។

ដោយហេតុដូចនេះ ដើម្បីអោយការគ្រប់គ្រងថវិកាប្រកបដោយប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវណែនាំទីចាត់ការគយ និងរដ្ឋាករអោយពង្រឹង និងជំរុញថែមទៀតនូវការទប់ស្កាត់ និងបង្ក្រាបអំពើរត់ពន្ធគ្រប់ប្រភេទ ពិសេសនៅចំណុចដើមទីអោយបានម៉ឺងម៉ាត់ ។

ឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា ក្រសួងសូមឯកភាពមួយភាគធំលើអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ហើយក្រសួងនឹងខិតខំជំរុញបន្ថែមទៀតលើការងារនេះអោយបានកាន់តែល្អប្រសើរ ។ ដើម្បីទប់ស្កាត់បញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចាត់វិធានការអោយទីចាត់ការគយ និងរដ្ឋាករពង្រឹងបណ្តាសាខាការិយាល័យកណ្តាលទី និងចុងទី ចូលរួមយ៉ាងសកម្មក្នុងការបង្ក្រាបអំពើរត់ពន្ធនេះ ។

ដោយផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិមានជំនឿថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាព មិនចំពោះតែនៅចំណុចកណ្តាលទី និងចុងទីប៉ុណ្ណោះទេ តែត្រូវបានយកចិត្តទុកដាក់ចំពោះមាត់ច្រកនាំចូលនៅដើមទីផងដែរ ។

### ៤.១.២ វិក្កយបត្រ និងបញ្ជីវេចខ្ចប់ទំនិញនាំចូល

ទំនិញដែលបាននាំចូលមកក្នុងប្រទេស មួយចំនួនត្រូវបាននាំចូលតាមរយៈក្រុមហ៊ុនធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក និងមួយចំនួនទៀតត្រូវបាននាំចូលតាមរយៈទីចាត់ការគយ និងរដ្ឋាករ ។ ការនាំចូលតាមរយៈក្រុមហ៊ុនធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុកដែលបានចុះកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាល ទំនិញទាំងអស់បានស្ថិតនៅក្រោមការធ្វើអធិការកិច្ចទៅលើឯកសារប្រកាសអំពីតំលៃ បរិមាណ និងយថាប្រភេទទំនិញជាក់ស្តែងនៅមុនការផ្ទុក និងចាក់សោរផ្លុមបេកុងតឺន័រ ។ ចំណែកឯទំនិញដែលត្រូវបាននាំចូលតាមរយៈទីចាត់ការគយនិងរដ្ឋាករ គឺមានការតំរូវអោយក្រុមហ៊ុន ឬបុគ្គលនាំចូលទាំងអស់ យកវិក្កយបត្រ និងបញ្ជីវេចខ្ចប់ទំនិញនាំចូលព្រមទាំងឯកសារពាក់ព័ន្ធផ្សេងៗ មកសុំការកំណត់តំលៃគិតពន្ធគយនៅទីចាត់ការគយ និងរដ្ឋាករ ឬសមត្ថកិច្ចគយតាមមាត់ច្រកនាំចូលនានា ដើម្បីទទួលបានការអនុញ្ញាតអោយនាំចូល ដោយផ្អែកលើការប្រកាសរបស់ម្ចាស់ទំនិញជាមូលដ្ឋាន ។

សេចក្តីណែនាំលេខ ០០១ សហវ. ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការបញ្ជាក់បន្ថែម និងការកែសំរួលនីតិវិធីនៃការកំណត់តំលៃពន្ធគយ បានកំណត់ថា រាល់ឯកសារដែលត្រូវយកទៅស្នើសុំការកំណត់តំលៃគិតពន្ធគយតាមរយៈទីចាត់ការគយ និងរដ្ឋាករ ត្រូវជាឯកសារច្បាប់ដើម ឬច្បាប់ចម្លង ដែលមានការបញ្ជាក់ទទួលស្គាល់ពីក្រុមហ៊ុន... ។

តាមការសង្កេតកន្លងមក សំណុំឯកសារ (វិក្កយបត្រ និងបញ្ជីវេចខ្ចប់ទំនិញនាំចូល) ដែលត្រូវបានយកមកសុំការកំណត់តំលៃគិតពន្ធគយតាមរយៈទីចាត់ការគយ និងរដ្ឋាករទាំងនោះ ភាគច្រើនត្រូវបានទទួលស្គាល់ថា

ជាឯកសារដែលបង្កើតឡើងដោយក្រុមហ៊ុន ឬបុគ្គលនាំចូល ដែលក្នុងនោះ ឯកសារខ្លះគ្មានត្រា គ្មានហត្ថលេខារបស់ក្រុមហ៊ុនផ្គត់ផ្គង់ តែជាត្រារបស់ក្រុមហ៊ុននាំចូល គ្មានរាយលំអិតអំពីយថាប្រភេទ ទំហំ និងទំងន់នៃមុខទំនិញនីមួយៗច្បាស់លាស់ ការប្រកាសតំលៃទំនិញមានគំលាតពីគ្នាយ៉ាងច្រើនជាមួយនឹងតំលៃគយកំណត់ ឬតំលៃនៅលើទីផ្សារ។ល។ ម្យ៉ាងវិញទៀតនៅពេលនាំចូល ទំនិញមួយចំនួនត្រូវបានផ្ទុកក្នុងកុងតឺន័រធំៗ ហើយស្ថិតនៅក្រោមការត្រួតពិនិត្យដោយម៉ាស៊ីនស្កេន ដែលការត្រួតពិនិត្យតាមរយៈប្រព័ន្ធម៉ាស៊ីននេះពុំអាចផ្តល់អោយដឹងនូវយថាប្រភេទ និងចំនួនទំនិញផ្ទុកនៅក្នុងកុងតឺន័រច្បាស់លាស់ទេ រីឯទំនិញមួយចំនួនដែលស្ថិតនៅក្រោមការត្រួតពិនិត្យដោយរូបវន្ត ជាទូទៅធ្វើក្នុងកំរិតពី ៥% ទៅ ២៥% ប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ ដើម្បីបង្កើនការប្រមូលចំណូលពន្ធអោយបានកាន់តែប្រសើរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរកំណត់យន្តការស្តីពីការប្រើប្រាស់ឯកសារនាំចូលអោយបានច្បាស់លាស់ និងការត្រួតពិនិត្យទំនិញអោយបានហ្មត់ចត់ថែមទៀត ។

ឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា បញ្ហាដែលអាជ្ញាធរសវនកម្មជាតិលើកឡើងអាចជាការពិត តែក្នុងនោះ ក៏ជាការលំបាកក្នុងការកំណត់ថា តើវិក្កយបត្រណាជាវិក្កយបត្រត្រឹមត្រូវ ឬច្បាប់ដើម។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងជំរុញទីចាត់ការគយ និងរដ្ឋាករអោយខិតខំពង្រឹងសមត្ថភាពការងារត្រួតពិនិត្យតាមក្រោយបន្ថែមទៀត ដើម្បីអនុវត្តកិច្ចការនេះអោយមានប្រសិទ្ធភាព ។

ដោយផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិរំពឹងទុកថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងពង្រឹងការត្រួតពិនិត្យលើការនាំចូលអោយកាន់តែសុក្រឹតថែមទៀត។ ជាមួយគ្នានេះដែរ អាជ្ញាធរសវនកម្មជាតិនៅតែសូមអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំណត់យន្តការនៃការប្រើប្រាស់ឯកសារនាំចូលអោយបានច្បាស់លាស់ គួបផ្សំនឹងការធានាអះអាងរបស់អ្នកនាំចូលទៅលើការប្រកាសទំនិញអោយបានជាក់លាក់ ។

## ៤.១.៣ ការគ្រប់គ្រងឃ្លាំងទំនិញនៅប៉ោយប៉ែត

នៅតាមច្រកទ្វារគយដែលមានសកម្មភាពនាំទំនិញចូលច្រើន ចំណូលពន្ធខ្ពស់ និងមានលក្ខណៈជាច្រកទ្វារអន្តរជាតិ ចាំបាច់ត្រូវមានឃ្លាំងស្តុកទំនិញ ឬទីលានឃ្លាំងរបស់រដ្ឋ ឬឯកជនស្របច្បាប់ណាមួយដែលមានលក្ខណៈគ្រប់គ្រង និងការទទួលខុសត្រូវច្បាស់លាស់ដោយរដ្ឋបាលគយ ដូចមាននៅមាត់ច្រកកំពង់ផែក្រុង-ព្រះសីហនុ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងកំពង់ផែភ្នំពេញ ជាដើម។ ដោយឡែក ចំពោះច្រកទ្វារព្រំដែនប៉ោយប៉ែត ដែលស្ថិតក្នុងចំណោមច្រកទ្វារមានការនាំទំនិញចូលច្រើន និងមានចំណូលពន្ធខ្ពស់ដែរនោះ បច្ចុប្បន្នមានតែឃ្លាំងទំនិញជាលក្ខណៈឯកជនប៉ុណ្ណោះ។ លើសពីនេះទៀត ឃ្លាំងទំនិញទាំងនោះ គ្មានឈ្មោះ គ្មានស្លាកសញ្ញាសំគាល់ច្បាស់លាស់ និងមិនត្រូវបានស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យពេញលេញដោយរដ្ឋបាលគយនោះទេ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ម្ចាស់ឃ្លាំង។ រដ្ឋបាលគយមានសមត្ថកិច្ចប្រចាំការនៅមាត់ច្រកនេះ ពុំមានរបាយការណ៍តាមដានទំនិញបញ្ចូល-បញ្ចេញឃ្លាំង កំណត់ហេតុត្រួតពិនិត្យស្តុកទំនិញ និងស្ថិតិឃ្លាំងស្តុកទំនិញច្បាស់លាស់ឡើយ ។

អាស្រ័យដូចនេះ ដើម្បីគ្រប់គ្រងទំនិញនាំចូល និងប្រមូលពន្ធអោយបានហ្មត់ចត់ និងអស់លទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរពិនិត្យលទ្ធភាពអំពីការបង្កើតអោយមានឃ្លាំងទំនិញរបស់រដ្ឋ ឬរបស់ឯកជន ស្របច្បាប់ណាមួយ ដែលមានប្រព័ន្ធត្រួតពិនិត្យ និងគ្រប់គ្រងច្បាស់លាស់ដោយរដ្ឋបាលគយ ។

ចំពោះការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានមតិថា ក្រសួងសូមឯកភាពលើ អនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ព្រោះនេះជាការចាំបាច់តាមនីតិវិធីគយជាធរមាន ដែលតម្រូវអោយ មានឃ្លាំង និងទីលានដែលគ្រប់គ្រងដោយគយសំរាប់បំរើអោយការគ្រប់គ្រងត្រួតពិនិត្យបែបបទគយប្រកបដោយ ប្រសិទ្ធភាព។ រហូតមកទល់បច្ចុប្បន្ននេះ នៅតាមបណ្តាមាត់ច្រកគយសំខាន់ៗមួយចំនួនពុំទាន់មានឃ្លាំង និង ទីលានដែលគ្រប់គ្រងដោយគយទេ។ ការងារនេះ តម្រូវអោយមានការជំរុញរកទីតាំងគយសមស្របតាមព្រំដែន ដើម្បីបង្កើតអោយមានហេដ្ឋារចនាសម្ព័ន្ធដូចនេះ ។

ផ្អែកលើការបំភ្លឺនេះ និងដោយស្ថិតក្នុងករណីចាំបាច់ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងប្រញាប់ប្រញាល់រកដំណោះស្រាយធ្វើការផ្លាស់ប្តូរស្ថានភាពនេះអោយបានឆាប់ តាមដែលអាច ធ្វើបាន ។

## ៤.១.៤ កិច្ចសហការការងាររវាងនាយកដ្ឋានពន្ធដារ និងទីចាត់ការគយ និងរដ្ឋាករ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំណត់នៅក្នុងការធ្វើអាជីវកម្មនាំចេញ-នាំចូលទំនិញមានលក្ខណៈ ពាណិជ្ជកម្ម គឺអាចធ្វើទៅបានចំពោះតែបុគ្គលដែលមានលេខអត្តសញ្ញាណកម្មអាករលើតំលៃបន្ថែម(អ.ត.ប) និងប័ណ្ណប៉ាតង់ប្រចាំឆ្នាំប៉ុណ្ណោះ។ ក្នុងនោះ ក្រុមហ៊ុន-សហគ្រាសត្រូវអនុវត្តកាតព្វកិច្ចពន្ធដូចជាការបង់ពន្ធ និង ការប្រកាសពន្ធអោយបានត្រឹមត្រូវ និងទៀងទាត់ ទើបមានឈ្មោះ ឬអត្តសញ្ញាណក្រុមហ៊ុនក្នុងបញ្ជីចរន្តរបស់ នាយកដ្ឋានពន្ធដារ និងទទួលបានសិទ្ធិធ្វើសកម្មភាពអាជីវកម្មស្របតាមច្បាប់កំណត់។ នៅក្នុងឆ្នាំ២០០២ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំលេខ ០០៤ សហវ.ពដ ចុះថ្ងៃទី០៦ ខែមិថុនា ស្តីពីការអនុវត្តន៍ ប្រកាសបង្កើតក្រុមការងាររវាងនាយកដ្ឋានពន្ធដារ និងទីចាត់ការគយ និងរដ្ឋាករ ដើម្បីធ្វើកិច្ចសហការព័ត៌មាន និងទិន្នន័យ បញ្ជីឈ្មោះអ្នកជាប់ពន្ធទៅវិញទៅមក សំដៅងាយស្រួលគ្រប់គ្រងទប់ស្កាត់ និងបង្ក្រាបអំពើរត់គេច វេះពន្ធដារ និងពន្ធគយផ្សេងៗបានទាន់ពេលវេលា។ តាមការសង្កេតកន្លងមកឃើញថា មានក្រុមហ៊ុន-សហគ្រាស មួយចំនួនមិនបានមកប្រកាសពន្ធអោយបានត្រឹមត្រូវតាមការកំណត់ ខ្លះទៀតបានសុំឈប់ ខ្លះសុំផ្អាកអាជីវកម្ម ហើយត្រូវបាននាយកដ្ឋានពន្ធដារដកចេញពីបញ្ជីចរន្ត ប៉ុន្តែជាក់ស្តែងក្រុមហ៊ុន-សហគ្រាសទាំងនោះនៅតែអាច ធ្វើសកម្មភាពនាំទំនិញចូលបានជាប្រក្រតី។ ជាអាទិ៍ក្នុងឆ្នាំ២០០៦ មានជិតមួយរយក្រុមហ៊ុន-សហគ្រាស ដែលពុំមានឈ្មោះក្នុងបញ្ជីចរន្តរបស់នាយកដ្ឋានពន្ធដារ ប៉ុន្តែបានធ្វើសកម្មភាពនាំទំនិញចូល ។

ដោយហេតុនេះ ដើម្បីទប់ស្កាត់ការគេចវេះពន្ធ និងគ្រប់គ្រងការប្រមូលពន្ធអោយបានល្អ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវណែនាំដល់អង្គភាពក្រោមឱវាទទាំងពីរធ្វើកិច្ចសហការព័ត៌មាន និងទិន្នន័យ អោយ បានទាន់ពេលវេលា ព្រមទាំងគ្រប់គ្រងសកម្មភាពក្រុមហ៊ុន-សហគ្រាសអោយបានហ្មត់ចត់ ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានមតិថា ក្រសួងសូមឯកភាពមួយផ្នែកលើការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ប៉ុន្តែទោះយ៉ាងណាក៏ដោយក្រសួងសូមបំភ្លឺបន្ថែមថា ករណីនេះកើតឡើងដោយសារនាយកដ្ឋានពន្ធដារបានផ្ញើលេខអត្តសញ្ញាណកម្មអាករលើតំលៃបន្ថែម(VAT-TIN) របស់ក្រុមហ៊ុន-សហគ្រាស ដល់ទីចាត់ការគយ និងរដ្ឋាករក្នុងរយៈពេល ៣ខែម្តង។ ក្នុងចន្លោះនៃការផ្ញើទិន្នន័យផ្លូវការ ៣ខែ ម្តងនេះ អាចបង្កអោយមានគម្លាតទិន្នន័យរវាងអង្គភាពប្រតិបត្តិទាំងពីរ។ ដើម្បីជៀសវាងនូវការមិនសូវស៊ីសង្វាក់ក្នុងការគ្រប់គ្រងទិន្នន័យក្រុមហ៊ុន-សហគ្រាសនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយល់ថា ការសំរេចលុបចោលពីបញ្ជីចរន្តនូវក្រុមហ៊ុន សហគ្រាសណាមួយ ត្រូវបញ្ជូនមកទីចាត់ការគយ និងរដ្ឋាករភ្លាម មិនត្រូវរង់ចាំដល់៣ខែ នោះទេ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងដាក់វិធានការអោយទីចាត់ការគយ និងរដ្ឋាករលើកសំណើនេះដើម្បីពិភាក្សា ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងណែនាំដល់អង្គភាពទាំងពីរអនុវត្តអោយបានពេញលេញ និងមានប្រសិទ្ធភាពតាមសារាចរណែនាំលេខ០០៤ និងការលើកឡើងរបស់ក្រសួងខាងលើ ។

## ៤.១.៥ ការគ្រប់គ្រងការប្រកាសពន្ធ

គ្រប់ក្រុមហ៊ុន-សហគ្រាសដែលស្ថិតនៅក្រោមការគ្រប់គ្រងរបបស្វ័យប្រកាស គឺមានការតំរូវអោយដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ ជូនរដ្ឋបាលសារពើពន្ធតាមកាលកំណត់ច្បាស់លាស់។ នាយកដ្ឋានពន្ធដារមានភារកិច្ចធ្វើការតាមដានត្រួតពិនិត្យលើឯកសារប្រកាសពន្ធទាំងនោះ ដើម្បីស្វែងរកការប្រកាសពន្ធដែលមានភាពមិនប្រក្រតីបញ្ចូលក្នុងកម្មវិធីសវនកម្ម ហើយធ្វើការពិនិត្យបញ្ជាក់សារពើពន្ធឡើងវិញ។ ក្នុងឆ្នាំ២០០៦ មានចំនួនជាងប្រាំពាន់ក្រុមហ៊ុន-សហគ្រាស បានមកប្រកាសពន្ធនៅនាយកដ្ឋានពន្ធដារ។ ក្នុងនោះ អាជ្ញាធរសវនកម្មជាតិបានត្រួតពិនិត្យលើលិខិតប្រកាសពន្ធរបស់ក្រុមហ៊ុន-សហគ្រាស ជាងម្ភៃក្រុមហ៊ុន-សហគ្រាស ឃើញមានជាងដប់ក្រុមហ៊ុន-សហគ្រាស បានប្រកាសផលរបរមិនត្រឹមត្រូវ។ ដោយក្រុមហ៊ុន-សហគ្រាសខ្លះប្រកាសផលរបរសរុប ១២ខែ តូចជាងផលរបរប្រចាំឆ្នាំ និងខ្លះទៀតប្រកាសផលរបរសរុប ១២ខែ ធំជាងផលរបរប្រចាំឆ្នាំ ហើយលើសពីនេះទៀត រហូតមកដល់ថ្ងៃធ្វើសវនកម្ម (ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៧) ក្រុមហ៊ុន-សហគ្រាសទាំងនោះ ពុំទាន់បានបញ្ចូលក្នុងកម្មវិធីសវនកម្មនៅឡើយទេ ។

អាស្រ័យដូចនេះ ដើម្បីគ្រប់គ្រងសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន-សហគ្រាស និងការប្រមូលពន្ធអោយបានត្រឹមត្រូវ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំនាយកដ្ឋានពន្ធដារពង្រឹងការត្រួតពិនិត្យការប្រកាសពន្ធរបស់ក្រុមហ៊ុន-សហគ្រាសអោយបានទាន់ពេលវេលា ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា របបឆ្លើយប្រកាសក្រុមហ៊ុន-សហគ្រាសជាអ្នកឆ្លើយប្រកាសដោយខ្លួនឯង។ ការខុសគ្នានេះ អាចបណ្តាលមកពីក្រុមហ៊ុន-សហគ្រាសប្រើប្រាស់គណនីបង្គរជាមូលដ្ឋាន ដើម្បីទទួលស្គាល់ជាចំណូលដែលកើតមានឡើង ប៉ុន្តែមិនទាន់បានចេញវិក្កយបត្រ

នៅឡើយ ។ តាមការត្រួតពិនិត្យឯកសាររបស់ក្រុមហ៊ុន-សហគ្រាសឃើញមានការខុសគ្នា រវាងការប្រកាសប្រចាំខែ និងប្រចាំឆ្នាំនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងចាត់វិធានការជំរុញអោយនាយកដ្ឋានពន្ធដារពិនិត្យបញ្ចូលក្រុមហ៊ុន-សហគ្រាសទាំងនេះទៅក្នុងកម្មវិធីសវនកម្ម ដើម្បីធ្វើការពិនិត្យអំពីភាពត្រឹមត្រូវនៃការប្រកាស ។ ករណីមានការបន្លំគេចពន្ធ សវនករនឹងធ្វើការកំណត់ពន្ធឡើងវិញតាមច្បាប់ ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងពង្រឹងបន្ថែមទៀត លើការត្រួតពិនិត្យឯកសារការប្រកាសពន្ធនៅនឹងកន្លែង ដើម្បីស្វែងរកភាពមិនប្រក្រតីនៃការប្រកាស ហើយបញ្ចូលក្នុងកម្មវិធីសវនកម្ម និងធ្វើការត្រួតពិនិត្យបញ្ជាក់ពន្ធឡើងវិញបានទាន់ពេលវេលា ។

## ៤.១.៦ ការចុះអាជីវកម្មដ្ឋានតាមរបបម៉ៅការក្នុងបញ្ជីអនុម័តពន្ធ

ការចុះអាជីវកម្មដ្ឋានតាមរបបម៉ៅការក្នុងបញ្ជីអនុម័តពន្ធ គឺជាមូលដ្ឋានចាំបាច់ក្នុងការប្រមូលពន្ធពីអាជីវកម្មដ្ឋានតាមរបបម៉ៅការទាំងឡាយ ។ មន្ត្រីពន្ធដារអាចប្រមូលពន្ធពីអាជីវកម្មដ្ឋានតាមរបបម៉ៅការបានលុះត្រាតែអាជីវកម្មដ្ឋានទាំងនោះត្រូវបានចុះក្នុងបញ្ជីអនុម័តពន្ធ ។ អង្គភាពពន្ធដារ មានតួនាទីធ្វើជំរឿនអ្នកជាប់ពន្ធ កំណត់ពន្ធ ប្រមូលពន្ធ ជារៀងរាល់ខែតាមបទប្បញ្ញត្តិនៃច្បាប់សារពើពន្ធ ប៉ុន្តែកន្លងមក អាជីវ-កម្មដ្ឋានមួយចំនួនមិនត្រូវបានបញ្ចូលក្នុងបញ្ជីអនុម័តនោះទេ ។ ជាអាទិ៍ក្នុងឆ្នាំ២០០៦នេះ តាមការធ្វើតេស្តលើមូលដ្ឋានអាជីវកម្មនៅតំបន់មួយចំនួននៃសាខាពន្ធដាររាជធានីភ្នំពេញ ក្រុងព្រះសីហនុ ខេត្តបន្ទាយមានជ័យ ក្រចេះ ព្រៃវែង និងកំពង់ធំ ឃើញថា មានអាជីវកម្មដ្ឋានជាងប្រាំពីររយមូលដ្ឋាន ពុំត្រូវបានបញ្ចូលក្នុងបញ្ជីអនុម័តពន្ធឡើយ ។

អាស្រ័យដូចនេះ ដើម្បីប្រមូលពន្ធអោយបានត្រឹមត្រូវ និងអស់លទ្ធភាព សាលាខេត្ត-ក្រុងត្រូវណែនាំសាខាពន្ធដារខេត្ត-ក្រុងបញ្ចូលអាជីវកម្មដ្ឋានក្នុងបញ្ជីអនុម័តពន្ធអោយបានគ្រប់ចំនួន និងទាន់ពេលវេលា ។

ចំពោះការលើកឡើងខាងលើ សាលាខេត្ត-ក្រុងពាក់ព័ន្ធបានបំភ្លឺថា សាលាខេត្ត-ក្រុងយល់ស្របជាមួយរបាយការណ៍សវនកម្ម និងបានជំរុញអោយសាខាពន្ធដារធ្វើការត្រួតពិនិត្យ និងកត់ត្រាមូលដ្ឋានអាជីវកម្មបញ្ចូលក្នុងបញ្ជីអនុម័តពន្ធជាបណ្តើរៗ ។ ប៉ុន្តែ ការចុះបញ្ជីមូលដ្ឋានអាជីវកម្មតាមរបបម៉ៅការ ពិតជាជួបនូវការលំបាក ព្រោះអាជីវកម្មដ្ឋានមួយចំនួនត្រូវបានបញ្ឈប់អាជីវកម្មមួយរយៈបន្ទាប់ពីការប្តូរទីលំនៅ ហើយជារៀងរាល់ឆ្នាំមូលដ្ឋានអាជីវកម្មថ្មីៗជាច្រើនបានចាប់ផ្តើមប្រកបអាជីវកម្ម ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា គ្រប់សាលាខេត្ត-ក្រុងនឹងជំរុញអោយមានការខិតខំចុះបញ្ជីអនុម័តពន្ធអោយបានកាន់តែប្រសើរ និងអស់លទ្ធភាព ។

## ៤.១.៧ ការប្រមូលពន្ធប្រថាប់ត្រា

ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ១៩៩៥ បានកំណត់ថា រាល់លិខិតមានលក្ខណៈគតិយុត្តិ ស្តីពីការបង្កើត រំសាយក្រុមហ៊ុន កិច្ចសន្យាផ្គត់ផ្គង់សេវា ឬសំភារៈទំនិញដល់អង្គភាពសាធារណៈ ត្រូវបង់ពន្ធប្រថាប់ត្រាដប់ម៉ឺនរៀល ។ ប៉ុន្តែកន្លងមក ការងារនេះពុំទាន់ត្រូវបានអនុវត្តអោយបានពេញលេញដូចច្បាប់បានកំណត់

នោះទេ។ ជាអាទិ៍ក្នុងឆ្នាំ២០០៦ ផ្អែកតាមការធ្វើសវនកម្មនៅសាលាខេត្តចំនួន ៥ និងតាមបណ្តាមន្ទីរ-ឃុំមួយចំនួន ឃើញថា មានកិច្ចសន្យាលទ្ធកម្មជាងមួយពាន់កិច្ចសន្យា ពុំមានការបង់ពន្ធប្រថាប់ត្រាឡើយ ។

អាស្រ័យហេតុនេះ ដើម្បីគ្រប់គ្រងប្រមូលពន្ធប្រថាប់ត្រាអោយបានត្រឹមត្រូវ និងអស់លទ្ធភាព សាលាខេត្ត-ក្រុងត្រូវណែនាំសាខាពន្ធដារ អង្គភាពលទ្ធកម្ម និងអង្គភាពពាក់ព័ន្ធនានាសហការអនុវត្តការប្រមូលពន្ធនេះអោយត្រឹមត្រូវតាមច្បាប់កំណត់ ។

ឆ្លើយតបនឹងការលើកឡើងខាងលើ សាលាខេត្តបានបំភ្លឺថា ជារួមសាលាខេត្តឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ហើយនឹងរិះរកវិធីក្នុងការប្រមូលពន្ធប្រថាប់ត្រានេះអោយកាន់តែល្អថែមទៀត ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា គ្រប់អង្គភាពពាក់ព័ន្ធនឹងធ្វើកិច្ចសហការជំរុញអោយការប្រមូលពន្ធប្រថាប់ត្រានេះ ប្រព្រឹត្តទៅបានល្អ និងស្របតាមច្បាប់កំណត់ ។

### ៤.១.៨ ពន្ធលើដីធ្លីមិនបានប្រើប្រាស់

ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ១៩៩៤ បានកំណត់ថា ភាពយឺតយ៉ាវមិនបានបង់ពន្ធអាករ នឹងអាចអនុគ្រោះ ពន្យាពេលបង់ពន្ធអាករ បន្ថយពន្ធអាករ ឬអាចរួចពន្ធអាករបាន តែក្នុងករណីមានមហន្តរាយដល់សកម្មភាពអាជីវកម្ម ឬទ្រព្យសម្បត្តិអ្នកជាប់ពន្ធអាករ ឬអាយុជីវិតរបស់អ្នកជាប់ពន្ធអាករ ហើយករណីចុងក្រោយ រដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាអ្នកសំរេច។ ប៉ុន្តែកន្លងមក ការងារដែលពាក់ព័ន្ធនឹងករណីនេះ មួយចំនួនពុំទាន់ត្រូវបានអនុវត្តអោយបានពេញលេញតាមច្បាប់បានកំណត់នោះទេ។ តាមការធ្វើសវនកម្មនៅសាខាពន្ធដាររាជធានីភ្នំពេញ និងនៅសាខាពន្ធដារក្រុងព្រះសីហនុសំរាប់ការិយបរិច្ឆេទ ២០០៦ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មានការលើកលែងប្រាក់ពន្ធ និងប្រាក់ពន្ធបន្ថែម សរុបជាងមួយរយ-ហាសិប ករណី ។

ដោយហេតុដូចនេះ ដើម្បីគ្រប់គ្រងការប្រមូលពន្ធអោយបានល្អប្រសើរ និងអនុវត្តអោយស្របតាមច្បាប់កំណត់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវណែនាំអំពីបែបបទនៃការលើកលែងប្រាក់ពន្ធ ឬប្រាក់ពន្ធបន្ថែមលើដីមិនបានប្រើប្រាស់អោយបានច្បាស់លាស់ ។

ចំពោះការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនបានឆ្លើយតបទេ ដូច្នេះត្រូវបានចាត់ទុកថាក្រសួងបានឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ។

### ៤.១.៩ ការបង្កើតបញ្ជីដីមិនបានប្រើប្រាស់

ចាប់តាំងពីឆ្នាំ១៩៩៦ ជាបន្តបន្ទាប់មក គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ តែងបានចេញលិខិតណែនាំអនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់តាមខេត្ត-ក្រុង ដោយកំណត់តួនាទីរបស់អនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ មានភារកិច្ចបង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងខេត្ត-ក្រុងរបស់ខ្លួន។ ប៉ុន្តែកន្លងមក ករណីនេះពុំទាន់ត្រូវបានអនុវត្តអោយបានពេញលេញនៅឡើយ ជាអាទិ៍ក្នុងឆ្នាំ២០០៦ តាមការធ្វើសវនកម្មនៅតាមបណ្តាខេត្ត-ក្រុងមួយចំនួន ដូចជា សាលាខេត្តបន្ទាយមានជ័យ សាលាខេត្តស្វាយរៀង

សាលាក្រុងព្រះសីហនុ សាលាក្រុងភ្នំពេញ ឃើញថា អនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ទាំងនេះ មិនបានបង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងខេត្ត-ក្រុងរបស់ខ្លួនទេ ។

អាស្រ័យដូចនេះ ដើម្បីគ្រប់គ្រងដីមិនបានប្រើប្រាស់អោយបានច្បាស់លាស់ និងប្រមូលពន្ធអោយបានត្រឹមត្រូវ អនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់តាមខេត្ត-ក្រុង ត្រូវបង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់នីមួយៗនៃខេត្ត-ក្រុងរបស់ខ្លួនអោយបានឆាប់រហ័ស និងទាន់ពេលវេលាស្របតាមការណែនាំរបស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ សាលាខេត្ត-ក្រុងមានមតិថា សាលាខេត្ត-ក្រុងសូមឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិរំពឹងថា សាលាខេត្ត-ក្រុងនឹងខិតខំបង្កើតបញ្ជីដីមិនបានប្រើប្រាស់អោយបានគ្រប់ចំនួន និងទាន់ពេលវេលា ដើម្បីគ្រប់គ្រងប្រមូលពន្ធផ្នែកនេះអោយបានប្រសើរ ។

## ៤.១.១០ ការកំណត់ថ្លៃឈ្នួលដីសម្បទាន

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជូសមុខអោយរាជរដ្ឋាភិបាល បានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនវិនិយោគជាង ៧០ ក្រុមហ៊ុនចាប់ពីឆ្នាំ១៩៩២ រហូតដល់ ឆ្នាំ២០០៦ លើផ្ទៃដីសម្បទានចំនួនជាង ១លានហិកតា ដើម្បីអភិវឌ្ឍន៍ ហើយកិច្ចព្រមព្រៀងទាំងនេះ ភាគច្រើនគឺមានសុពលភាពជាង ៧០ឆ្នាំ ។ នៅខែឧសភា ឆ្នាំ២០០០ ទីស្តីការគណៈរដ្ឋមន្ត្រីបានសំរេចថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកចុះទៅធ្វើការវាយតំលៃ និងកំណត់ថ្លៃឈ្នួលដី។ ប៉ុន្តែរហូតដល់ឆ្នាំ២០០៧ ការវាយតំលៃ និងការកំណត់ថ្លៃឈ្នួលដីសម្បទាន នៅពុំទាន់អនុវត្តអោយបានពេញលេញស្របតាមសេចក្តីសំរេចនេះនៅឡើយ ។

ដោយហេតុដូចនេះ ដើម្បីគ្រប់គ្រងប្រមូលចំណូលដីសម្បទានអោយបានប្រសើរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គួរសហការធ្វើការវាយតំលៃដី និងកំណត់ថ្លៃឈ្នួលដីសម្បទានអោយបានឆាប់តាមតែអាចធ្វើទៅបាន ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា ក្រសួងសូមឯកភាពតាមរបាយការណ៍របស់អាជ្ញាធរសវនកម្មជាតិ។ ជាមួយគ្នានេះ ក្រសួងនឹងមានវិធានការទទូចបន្តទៀតអោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេស គណៈកម្មការអន្តរក្រសួង ជំរុញ និងបង្កើនល្បឿនបន្ថែមទៀត ក្នុងការកំណត់ប្រភេទដីសម្បទានតាមភូមិសាស្ត្រជាក់ស្តែងនៃកិច្ចសន្យានីមួយៗ និងកំណត់ប្រភេទដំណាំ ដើម្បីចាត់ចែងប្រមូលចំណូលពីវិស័យនេះអោយបានទាន់ពេលវេលា។ ដោយឡែក ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបំភ្លឺថា រហូតមកទល់ពេលនេះ ផ្ទៃដីអាជីវកម្មសរុបរបស់ក្រុមហ៊ុនទាំងនោះពុំអាចកំណត់អោយបានពិតប្រាកដនៅឡើយ ដោយមូលហេតុ ស្ទើរតែគ្រប់ក្រុមហ៊ុនទាំងអស់កំពុងជួបប្រទះបញ្ហាទំនាស់ដីធ្លីជាមួយប្រជាពលរដ្ឋពុំទាន់ដោះស្រាយចប់ ករណីខ្លះហួសពីសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខា

ប្រមាញ់ និងនេសាទ ហើយក្រសួងបានប្រគល់ជូនអាជ្ញាធរដោះស្រាយទំនាស់ដីធ្លីជួយដោះស្រាយ ។ បច្ចុប្បន្ន ការគ្រប់គ្រងដីសម្បទានមានលក្ខណៈស្មុគស្មាញជាទីបំផុត ព្រោះប្រជាពលរដ្ឋបានចូលកាន់កាប់ផ្នែកខ្លះ ហើយ កន្លែងខ្លះទៀតក្រុមហ៊ុនពុំអាចបញ្ចូលគ្រឿងចក្រទៅដំណើរការដាំដុះបាន។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក៏ដោយ បន្ទាប់ពីមានការកែសំរួលសមាសភាពគណៈកម្មការអន្តរក្រសួងពី ០៧រូប ទៅ ១០រូបមក គណៈកម្មការនេះ បានដំណើរការការងាររបស់ខ្លួនជាបន្តបន្ទាប់។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កំពុងពិនិត្យ និងផ្តល់អនុសាសន៍ ដើម្បីកំណត់ថ្លៃឈ្នួលដីសម្បទាននេះអោយបានស្របតាមខ្លឹមសារ លិខិតលេខ ៨០៣ សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ជាសរុបមក ការ កំណត់យកថ្លៃឈ្នួលដីសម្បទានសេដ្ឋកិច្ចបច្ចុប្បន្នបាន នឹងកំពុងអនុវត្តដោយគណៈកម្មការអន្តរក្រសួងកំណត់ថ្លៃ ឈ្នួលដីសម្បទាន ប៉ុន្តែមានភាពយឺតយ៉ាវបន្តិច ព្រោះការងារនេះជាការលំបាក ស្មុគស្មាញ និងលក្ខណៈវិទ្យាសាស្ត្រ ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិមានការរំពឹងទុក និងស្នើដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈកម្មការអន្តរក្រសួងរៀបចំកំណត់ប្រភេទដីសម្បទាន អោយបានឆាប់រហ័ស និងទាន់ពេលវេលាស្របតាមកិច្ចព្រមព្រៀង ។

### ៤.១.១១ ការផ្ទេរថវិកាវិភាជន៍ជូនឃុំ

ថវិការបស់ឃុំបានមកពីចំណូលពន្ធមូលដ្ឋាន ចំណូលមិនមែនសារពើពន្ធ (ចំណូលពីសេវាកម្ម និង ទ្រព្យសម្បត្តិ ដូចជា កំរៃរដ្ឋបាល កំរៃប្រើប្រាស់សេវាមូលដ្ឋាន និងថ្លៃឈ្នួលអចលនទ្រព្យ...) និងថវិកា វិភាជន៍របស់រដ្ឋ។ យោងតាមបទប្បញ្ញត្តិ ថវិកាវិភាជន៍របស់រដ្ឋត្រូវតែផ្ទេរចូលថវិកាឃុំតាមរយៈរតនាគារខេត្ត ៣ដង ក្នុងមួយឆ្នាំ ÷

- លើកទី១ យ៉ាងតិច ៥០% ត្រឹមថ្ងៃទី៣១ ខែឧសភា
- លើកទី២ យ៉ាងតិច ៣០% ត្រឹមថ្ងៃទី៣១ ខែសីហា និង
- លើកទី៣ ចំនួន ២០% ត្រឹមថ្ងៃទី៣១ ខែតុលា

ប៉ុន្តែជាក់ស្តែងអាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ថវិកាវិភាជន៍របស់រដ្ឋមិនត្រូវបានផ្ទេរចូលថវិកាឃុំ ទាន់ពេលវេលាកំណត់នោះទេ ជាអាទិ៍ក្នុងឆ្នាំ២០០៦ បណ្តាឃុំនៃខេត្តកំពត តាកែវ ក្រចេះ បន្ទាយមានជ័យ និងខេត្តព្រៃវែង ទទួលបានការផ្ទេរថវិកាវិភាជន៍ (ការផ្តល់តួលេខពីរតនាគារជាតិទៅរតនាគារខេត្ត) ដូចខាង ក្រោម ÷

- លើកទី១ ទទួលបានក្នុងចន្លោះថ្ងៃទី២៩ ខែមីនា ដល់ថ្ងៃទី០៥ ខែមេសា ចំនួន ៤៤,៥០%
- លើកទី២ ទទួលបានក្នុងចន្លោះថ្ងៃទី១៥ ខែមិថុនា ដល់ថ្ងៃទី០៦ ខែកក្កដា ចំនួន ៥,៥០%
- លើកទី៣ ទទួលបានក្នុងចន្លោះថ្ងៃទី១១ ដល់ថ្ងៃទី២៦ ខែកក្កដា ចំនួន ៤៤,៥០%
- លើកទី៤ ទទួលបានក្នុងចន្លោះថ្ងៃទី១៥ ដល់ថ្ងៃទី២៧ ខែវិច្ឆិកា ចំនួន ៥,៥០%

ហើយរហូតដល់ចុងខែធ្នូ ទើបបណ្តាឃុំនៃខេត្តខាងលើបើកប្រាក់បានគ្រប់ចំនួន ២០.៤៣២ លានរៀល ដោយឆ្លងតាមរយៈនៃការបើកផ្តល់ចំនួន ១៦ លើក ។

អាស្រ័យដូចនេះ ក្រុមប្រឹក្សាឃុំត្រូវសហការជាមួយអង្គភាពរដ្ឋបាលមូលដ្ឋាន ដើម្បីស្នើសុំមកក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជួយជំរុញការផ្ទេរថវិកាវិភាជន៍អោយបានទាន់ពេលវេលា ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រុមប្រឹក្សាឃុំមានមតិថា ក្រុមប្រឹក្សាឃុំសូមឯកភាព និងសំណូមពរដល់ថ្នាក់ជាតិអោយជួយផ្តល់ថវិកាវិភាជន៍បានទាន់ពេលវេលា ។

ផ្អែកតាមការបំភ្លឺ និងសំណូមពរនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ថ្នាក់ជាតិនឹងផ្តល់ថវិកាវិភាជន៍ជូនបណ្តាឃុំបានទាន់ពេលវេលាស្របតាមបទប្បញ្ញត្តិកំណត់ ។

## ៤.២ ការគ្រប់គ្រងចំណាយថវិកា

### ៤.២.១ ការបើកផ្តល់ប្រាក់មុនកាលកំណត់នៃកិច្ចសន្យា

លិខិតលេខ ៥៩៤៤ សហវ. ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការរៀបចំកិច្ចសន្យាលទ្ធកម្មក្នុងប្រការការទូទាត់ និងការធានាសុពលភាពសំណង់លើគំរោងជួសជុល និងសាងសង់ ដែលអនុវត្តដោយអង្គភាពរដ្ឋបានកំណត់ថា រាល់ការបើកផ្តល់ប្រាក់ក្នុងដំណាក់កាលទី១ជូនអង្គភាពរដ្ឋ "អ្នកទទួលការ" អាចប្រព្រឹត្តិទៅបានក្នុងរយៈពេល ៧ ថ្ងៃ បន្ទាប់ពីកិច្ចសន្យាចូលជាធរមាន។ ប៉ុន្តែ តាមការពិនិត្យលើកិច្ចសន្យាចំនួន៤១ ក្នុងចំណោម ៦២កិច្ចសន្យា ស្តីពីការជួសជុល និងថែទាំ ផ្លូវ-ស្ពាន ដែលអនុវត្តដោយអង្គភាពក្រោមចំណុះក្រសួងសាធារណការ និងដឹកជញ្ជូន នាការិយបរិច្ឆេទ២០០៥-២០០៦ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា មាន ១៥ កិច្ចសន្យាត្រូវបានក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បើកផ្តល់ប្រាក់ដំណាក់កាលទី១ អោយអ្នកទទួលការ មុនកិច្ចសន្យាទាំងនោះចូលជាធរមាន ។

ដោយហេតុដូចនេះ ដើម្បីអនុវត្តការចំណាយថវិការដ្ឋអោយកាន់តែមានប្រសិទ្ធភាព ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តអោយបានខ្ជាប់ខ្ជួនតាមខ្លឹមសារលិខិតលេខ ៥៩៤៤ ខាងលើ និងលក្ខខណ្ឌនៃការទូទាត់ដែលមានចែងក្នុងកិច្ចសន្យា ។

ឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងសាធារណការ និងដឹកជញ្ជូនបានបំភ្លឺថា ចំពោះការបើកផ្តល់ប្រាក់មុននេះ ដោយសារអង្គភាពទទួលការអនុវត្តការងារស្តាបនា-ជួសជុលផ្លូវ ស្ពានទាំងនេះសុទ្ធតែជាអង្គភាពរដ្ឋ រួមមាន មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង អង្គភាពវិស្វកម្ម នាយកដ្ឋានវិស្វកម្ម។ល។ ដែលអង្គភាពទាំងនោះមិនមានថវិកាសំរាប់ចាប់ផ្តើមអនុវត្តការងារទេ។ ហេតុនេះហើយ ទើបក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញ លិខិតណែនាំលេខ៣៥៦៧ សហវ.វស ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០២ បញ្ជាក់បន្ថែមលើបែបបទ និងនីតិវិធីនៃការប្រើប្រាស់មូលនិធិសំរាប់ជួសជុល និងថែទាំផ្លូវថ្នល់ និងលិខិតណែនាំលេខ ៣៣៦៣ សហវ.វស ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០២ ដើម្បីពង្រឹងការអនុវត្តន៏គោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុចំពោះការចំណាយថវិកាជំពូក ៥០ (បច្ចុប្បន្នជំពូក២១) ដោយកងវិស្វកម្មដែលក្នុងនោះក៏មានកំណត់ថវិកាបុរេប្រទានជំហានដំបូងអតិបរមា ២០% ឬ ៣០% ទៅតាមគំរោង និងប្រភេទការងារ ដើម្បីអោយអង្គភាពទាំងនោះអាចចាប់ដំណើរការបានទាន់ពេលវេលា និងទាន់រដូវកាលក្នុងពេលកំពុងរៀបចំបែបបទអនុវត្តនីតិវិធី

លទ្ធកម្ម។ ប៉ុន្តែ ជាគោលការណ៍ក្នុងកិច្ចសន្យាដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំណត់ គឺត្រូវទូទាត់ជូន " ភាគីអ្នកទទួលការ " ចំនួន ៤០% នៃតំលៃកិច្ចសន្យា បន្ទាប់ពីកិច្ចសន្យាចូលជាធរមាន ៧ ថ្ងៃ ( លិខិតលេខ ៥៩៤៤ សហវ ចុះថ្ងៃ ទី២២ ខែកញ្ញា ឆ្នាំ២០០៥) ។ ក្រៅពីនេះ ការបើកផ្តល់ថវិកាជំហានទី១ ( បុរេប្រទាន) អោយអង្គភាពទាំងនោះ គឺសំដៅជំរុញការងារស្ថាបនា ជួសជុលផ្លូវ ស្ពានជាបន្ទាន់អោយទាន់ពេលវេលា ដើម្បីបំរើអោយការងារសង្គម និងអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ព្រមជាមួយគ្នានេះ បន្ទាប់ពីគ្រោះមហន្តរាយទឹកជំនន់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ តែងតែរងនូវការខូចខាត បាក់បែក ឬស្ពានបាក់ដោយចៃដន្យ ដែលការងារទាំងនេះទាមទារនូវថវិកាបុរេប្រទានផ្តល់មុនមួយចំនួន ដើម្បីជួសជុល ស្តារផ្លូវ ស្ពាន អោយចរាចរដំណើរការឡើងវិញជាប្រក្រតី និងទាន់ពេលវេលាដែរ ។

ឆ្លងតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសូមបញ្ជាក់បន្ថែមថា ចំពោះកិច្ចសន្យាទាំង ១៥ ដែលបានលើកឡើងខាងលើ ពុំស្ថិតក្នុងករណីបន្ទាន់ ករណីប្រធានសក្តិ ឬអនុវត្តដោយអង្គភាពវិស្វកម្មនោះទេ ដូចនេះក្រសួងទាំងពីរ គួរអនុវត្តអោយស្របតាមលិខិតលេខ ៥៩៤៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលក្ខខណ្ឌនៃកិច្ចសន្យា ។

## ៤.២.២ ការចូលរួមរបស់គណៈកម្មការលទ្ធកម្មឃុំ

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់អនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងគោលបំណងជំរុញអោយមានកិច្ចអភិវឌ្ឍន៍នៅមូលដ្ឋាន សំដៅដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ កិច្ចអភិវឌ្ឍន៍មូលដ្ឋានឃុំ សង្កាត់នេះ ត្រូវស្ថិតនៅក្រោមការដឹកនាំរបស់គណៈកម្មការលទ្ធកម្មរបស់ឃុំ សង្កាត់ ដែលក្នុងនោះមានមេឃុំ ចៅសង្កាត់ជាប្រធាន និងមានមន្ត្រីគាំទ្របច្ចេកទេសជាជំនួយការសំរាប់ចាត់ចែងដំណើរការការងារលទ្ធកម្ម ចាប់តាំងពីការរៀបចំឯកសារ ការផ្សព្វផ្សាយ ការអញ្ជើញចូលរួមដេញថ្លៃ ការលក់ឯកសារ ការទទួលឯកសារ ការបើកឯកសារ និងប្រគល់កិច្ចសន្យា។ ប៉ុន្តែ ឆ្លងតាមការធ្វើសវនកម្មនៅឃុំមួយចំនួននៃខេត្តកំពត តាកែវ ក្រចេះ បន្ទាយមានជ័យ និងខេត្តព្រៃវែង សំរាប់ការិយបរិច្ឆេទ២០០៦ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា គណៈកម្មការលទ្ធកម្មរបស់ឃុំមួយចំនួនមិនបានចូលរួមក្នុងដំណើរការកិច្ចលទ្ធកម្មអោយបានពេញលេញឡើយ ដូចជា ការចូលរួមរៀបចំឯកសារដេញថ្លៃ ការផ្សព្វផ្សាយ ការចូលរួមក្នុងការដេញថ្លៃ ការលក់ឯកសារ និងការទទួលឯកសារជាដើម ។

អាស្រ័យហេតុនេះ ដើម្បីអោយការអនុវត្តន៍គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលដំណើរការបានល្អគ្រប់ជ្រុងជ្រោយ គណៈកម្មការលទ្ធកម្មឃុំនៃខេត្តត្រូវចូលរួមអោយបានពេញលេញនៅក្នុងការអនុវត្តន៍កិច្ចលទ្ធកម្មរបស់ឃុំ ។

ចំពោះការលើកឡើងខាងលើ ក្រុមប្រឹក្សាឃុំបានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ ។

ដោយផ្អែកលើមតិនេះ អាជ្ញាធរសវនកម្មជាតិរំពឹងថា គណៈកម្មការលទ្ធកម្មរបស់ឃុំ-សង្កាត់នឹងចូលរួមក្នុងដំណើរការកិច្ចលទ្ធកម្មយ៉ាងខ្ជាប់ខ្ជួន ។

### ៤.២.៣ ការដកប្រាក់រង្វាន់សំរាប់ការលើកទឹកចិត្ត

ដើម្បីជាការលើកទឹកចិត្តនៅក្នុងការទប់ស្កាត់ និងការបង្រ្កាប អំពើរត់ពន្ធ ការគេចវេះពន្ធ និងការអនុវត្តនីចំណូលលើសផែនការដែលបានកំណត់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីគយ និងពន្ធដារ ព្រមទាំងជនទាំងឡាយណាដែលបានចូលរួមសហការ ។ នាឆ្នាំកន្លងមក ក៏ដូចក្នុងឆ្នាំ២០០៦ នេះ ទឹកប្រាក់រង្វាន់លើកទឹកចិត្តដែលបានដកពីចំណូលពន្ធគយ និងពន្ធដារទាំងនោះ ពុំត្រូវបានកត់ត្រាចូលក្នុងថវិការដ្ឋឡើយ ។

អាស្រ័យហេតុនេះ ដើម្បីអោយបានស្របតាមគោលការណ៍ហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវអនុវត្តអោយបានត្រឹមត្រូវតាមមាត្រា១១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ១៩៩៣ ដែលចំណូលត្រូវកត់ត្រាចូលទាំងស្រុង មិនត្រូវទូទាត់ជាមួយចំណាយឡើយ និងសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រីលេខ ១៤៩០ សជណ.សរ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៩ ដែលបានបញ្ជាក់ថា ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តអាចប្រព្រឹត្តទៅបាន ប៉ុន្តែត្រូវកត់ត្រាចូលក្នុងថវិការដ្ឋ ។

ឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា ដើម្បីជំរុញការងារស្រាវជ្រាវ និងបង្ក្រាបអំពើរត់ពន្ធអោយមានប្រសិទ្ធភាព និងជាការលើកទឹកចិត្តអោយទាន់ពេលវេលាដល់អ្នកចូលរួមអនុវត្តផ្ទាល់ និងបណ្តាអង្គភាពចូលរួមសហការ ការគ្រប់គ្រងប្រាក់រង្វាន់ត្រូវបានធ្វើឡើងតាមរយៈប្រកាសលេខ ០៣២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ និងសេចក្តីជូនដំណឹងលេខ ១៤៩០ សជណ.សរ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដែលអនុញ្ញាតអោយផ្តល់រង្វាន់លើកទឹកចិត្តភ្លាមៗ ក៏ប៉ុន្តែត្រូវកត់ត្រាចូលក្នុងថវិការដ្ឋ ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងអនុវត្តតាមការលើកឡើងខាងលើ ដោយធ្វើការកត់ត្រាចូលក្នុងថវិការដ្ឋអោយបានត្រឹមត្រូវស្របតាមច្បាប់កំណត់ ។

### ៤.២.៤ រយៈពេលកំណត់ក្នុងការទទួល និងទូទាត់អាណត្តិបើកប្រាក់

នៅឆ្នាំសារពើពន្ធនីមួយៗ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែងបានដាក់ឱសានវាទដល់រតនាគារជាតិ និងរតនាគារខេត្ត-ក្រុងទាំងអស់ ត្រូវឈប់ទទួលអាណត្តិបើកប្រាក់ត្រឹមវេលាម៉ោងដប់ប្រាំពីរ និងសាមសិបនាទីនាថ្ងៃទី២៩ ខែធ្នូ ដើម្បីធ្វើការបិទបញ្ជីចំណូល-ចំណាយ និងបូកសរុបរបាយការណ៍សំរេចទូទាត់ថវិកាប្រចាំឆ្នាំ ។ មាត្រា១០៩ នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ បានកំណត់ថា ការសន្យាដែលអាណត្តិបើកប្រាក់មិនបានប្រតិបត្តិការនៅថ្ងៃទី៣១ ខែធ្នូ ត្រូវបានកត់ត្រាជាបន្តចូលក្នុងឥណទានថវិកានៃឆ្នាំបន្ទាប់ ។ ប៉ុន្តែជាទូទៅ អាណត្តិបើកប្រាក់តែងបានបញ្ជូនទៅដល់រតនាគារជាតិយ៉ាងគំហុកនៅចុងឆ្នាំ ហើយការទទួលទូទាត់អាណត្តិបើកប្រាក់ដែលបញ្ជូនមកដល់រតនាគារជាតិក្រោយថ្ងៃកំណត់តែងបានអនុវត្តជារៀងរាល់ឆ្នាំ ។ ក្នុងឆ្នាំ២០០៦ រតនាគារជាតិបានទទួលទូទាត់អាណត្តិបើកប្រាក់ (រដ្ឋបាលកណ្តាល) ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានបញ្ជូនមកដល់ក្រោយថ្ងៃកំណត់មានចំនួនជាងប្រាំពីររយអាណត្តិ ដែលមានទឹកប្រាក់ជាងមួយរយពាន់លានរៀល ។

អាស្រ័យដូចនេះ ដើម្បីអនុវត្តអោយបានស្របតាមប្រកាសស្តីពីការបិទបញ្ជី ចំណូល-ចំណាយថវិកាប្រចាំឆ្នាំ និងមាត្រា១០៩ នៃអនុក្រឹត្យលេខ៨២ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរួសរាន់ក្នុងការបញ្ជូនអាណត្តិបើកប្រាក់ទៅរតនាគារជាតិអោយបានទាន់ពេលវេលា និងជៀសវាងការបញ្ជូនអាណត្តិយ៉ាងគំហុកនៅចុងឆ្នាំ ។

ឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានមតិថា ក្រសួងសូមឯកភាពដូចការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ។ ប៉ុន្តែ ចំពោះការដែលរតនាគាជាតិនៅតែទទួលទូទាត់អាណត្តិបើកប្រាក់ក្រោយថ្ងៃកំណត់ គឺអាស្រ័យដោយនៅក្នុងខែធ្នូ ក្រសួង-ស្ថាប័ននានាបានផ្ញើអាណត្តិបើកប្រាក់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងសន្ធឹកសន្ធាប់ ដែលតំរូវអោយក្រសួងធ្វើការប្រមូលផ្តុំដោះស្រាយនូវបណ្តុំចំណាយទាំងនោះ។ ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងធ្វើការពង្រឹងដល់គ្រប់ក្រសួង-ស្ថាប័ន អោយខិតខំជំរុញការអនុវត្តន៍ថវិកាអោយបានស្របតាមកម្មវិធីចំណូល-ចំណាយ ប្រចាំខែប្រចាំត្រីមាសនីមួយៗ ជៀសវាងមានអាណត្តិបើកប្រាក់មកកកកុញនៅចុងឆ្នាំ ។

ដោយផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងខិតខំបង្កើនល្បឿននៃការបញ្ជូនអាណត្តិ ដើម្បីអោយការទទួល និងការទូទាត់អាចប្រព្រឹត្តទៅបានស្របតាមកាលបរិច្ឆេទនៃឆ្នាំថវិកានីមួយៗ ។

## ៤.៣ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

### ការធ្វើប័ណ្ណសំគាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំណត់នៅក្នុងលិខិតលេខ ៥៣០១ សហវ.ទរ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣ អោយក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត-ក្រុង ធ្វើប័ណ្ណសំគាល់កម្មសិទ្ធិលើអចលនទ្រព្យអោយបានឆាប់រហ័ស។ ប៉ុន្តែតាមការសង្កេតក្នុងឆ្នាំកន្លងមក ឃើញថា ក្រសួង-ស្ថាបន័មួយចំនួនពុំទាន់ធ្វើប័ណ្ណសំគាល់កម្មសិទ្ធិលើអចលនទ្រព្យអោយបានគ្រប់ចំនួន ទាន់ពេលវេលានៅឡើយ។ ជាអាទិ៍ សំរាប់ការិយបរិច្ឆេទ២០០៦ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មនៅអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមួយចំនួន ដោយមានការកត់សំគាល់ដូចខាងក្រោម ÷

- ក្រសួងកិច្ចការនារីមិនបានធ្វើប័ណ្ណសំគាល់កម្មសិទ្ធិលើដី និងអគារដែលជាទ្រព្យសម្បត្តិរដ្ឋមានផ្ទៃក្រឡា ១៥.៤០០ម៉ែត្រការ៉េ ដែលក្នុងនោះត្រូវបានប្រជាជនកាន់កាប់អស់ចំនួន ១២.៤២៧ ម៉ែត្រការ៉េ

- សាកលវិទ្យាល័យភូមិន្ទកសិកម្មមិនបានធ្វើប័ណ្ណសំគាល់កម្មសិទ្ធិលើផ្ទៃដី ចំនួន ៣៨០ ហិកតា ដែលធ្វើអោយផ្ទៃដីចំនួន៣៥៥ហិកតា ត្រូវបានកាន់កាប់ដោយប្រជាពលរដ្ឋ

- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល មិនបានធ្វើប័ណ្ណសំគាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សៀមរាប បាត់ដំបង រតនគីរី មណ្ឌលគីរី កោះកុង ស្ទឹងត្រែង និងកងកេង

- សាលាខេត្តបន្ទាយមានជ័យមិនបានធ្វើប័ណ្ណសំគាល់កម្មសិទ្ធិលើអចលនទ្រព្យចំនួន ៣៤កន្លែង ស្មើនឹង ២០៧ ហិកតា

- សាលាខេត្តកំពតមិនបានធ្វើប័ណ្ណសំគាល់កម្មសិទ្ធិលើអចលនទ្រព្យចំនួន ៦ កន្លែង ស្មើនឹង ២,៨ ហិកតា

- អង្គភាពក្រោមចំណុះរបស់ខេត្តកំពង់ធំមួយចំនួនពុំបានធ្វើប័ណ្ណសំគាល់កម្មសិទ្ធិលើដីធ្លី និងអគារ ដែលជាកម្មសិទ្ធិរបស់រដ្ឋក្នុងនោះមាន សាលាស្រុកសណ្តាន់ សាលាស្រុកស្ទោង សាលាស្រុកកំពង់ស្វាយ សាលាស្រុកប្រាសាទសំបូរ និងសាលាស្រុកប្រាសាទបាល្ល័ង្គ ។

អាស្រ័យដូចនេះ ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋអោយបានគង់វង្ស និងមានប្រសិទ្ធភាព គ្រប់អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធ រួសរាន់ធ្វើប័ណ្ណសំគាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋអោយបានគ្រប់ចំនួន និងឆាប់រហ័ស ។

ចំពោះការលើកឡើងខាងលើ ក្រសួង-ស្ថាប័ន និងសាលាខេត្ត-ក្រុង ដែលជាអង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋភាគច្រើនបានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ រីឯរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានបំភ្លឺថា ដី BABALER (ដីនៅមុខព្រលានយន្តហោះអន្តរជាតិភ្នំពេញ) មិនបានធ្វើប័ណ្ណសំគាល់កម្មសិទ្ធិ ដោយសារវាបំរើអោយផ្នែកយោធា។ ចំពោះសាលាខេត្តកំពតមានបំណងចង់ធ្វើប័ណ្ណសំគាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិនេះដែរ ប៉ុន្តែមិនមានថវិកាសំរាប់ចំណាយក្នុងការធ្វើប័ណ្ណសំគាល់កម្មសិទ្ធិ ហើយសាលាខេត្តបានសំណូមពរទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីផ្តល់ថវិកាសំរាប់ចំណាយលើការធ្វើប័ណ្ណសំគាល់កម្មសិទ្ធិនេះ។ ដោយឡែក សាកលវិទ្យាល័យភូមិន្ទកសិកម្មកំពុងបន្តខិតខំដោះស្រាយហើយ តែមិនទាន់បានសំរេច ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធទាំងអស់ នឹងសហការធ្វើប័ណ្ណសំគាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរបស់រដ្ឋបានគ្រប់ចំនួន និងទាន់ពេលវេលា ។

## ៤.៤ កិច្ចបញ្ជីភាគណនេយ្យ

### ៤.៤.១ ការគ្រប់គ្រងហិរញ្ញប្បទានក្រៅរតនាគារជាតិ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានរាជរដ្ឋាភិបាលប្រគល់តួនាទី និងភារកិច្ចក្នុងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋប្រចាំឆ្នាំ ដើម្បីដាក់ជូនរដ្ឋសភាពិនិត្យ និងអនុម័ត។ នៅក្នុងការរៀបចំសេចក្តីព្រាងច្បាប់នៃឆ្នាំនីមួយៗ តែងមានលំអៀងតួលេខចំណូល-ចំណាយដោយហិរញ្ញប្បទានក្រៅប្រទេសអនុវត្តក្រៅរតនាគារជាតិ (អំពីកម្ចី និង អំណោយបរទេស) ដែលត្រូវបានប្រមូលទិន្នន័យពីគ្រប់ដៃគូអភិវឌ្ឍន៍ ក្រសួង-ស្ថាប័ន និងអង្គការនានា។ ដោយឡែក នៅក្នុងឆ្នាំ២០០៦ តួលេខចំណូល-ចំណាយដោយហិរញ្ញប្បទានក្រៅប្រទេសអំពីកម្ចីធនាគារពិភពលោកដែលអនុវត្តក្រៅរតនាគារជាតិ មានការកត់ត្រាលំអៀងលើស រីឯអំណោយបរទេស ពុំមានឯកសារបញ្ជាក់គ្រប់គ្រាន់ឡើយ ។

អាស្រ័យដូចនេះ ដើម្បីអោយការគ្រប់គ្រងនូវតួលេខចំណូល-ចំណាយដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិបានត្រឹមត្រូវ និងគណនេយ្យភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរបង្កើតយន្តការក្នុងការគ្រប់គ្រងប្រមូលទិន្នន័យចំណូល-ចំណាយហិរញ្ញប្បទានក្រៅប្រទេសអោយពេញលេញ និងទាន់ពេលវេលា ។

ចំពោះការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទទួលស្គាល់ថា មានការភ័ន្តច្រឡំ បច្ចេកទេសក្នុងការគណនា និងចុះលើសតួលេខចំណូល-ចំណាយក្រៅរតនាគារជាតិ។ រីឯឯកសារស្តីពីអំណោយហិរញ្ញប្បទានក្រៅប្រទេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នដទៃទៀតរបស់រាជរដ្ឋាភិបាល ក៏ពុំមានដែរ ព្រោះជាទូទៅ គំរោងទាំងនោះត្រូវបានអនុវត្តផ្ទាល់ដោយដៃគូអភិវឌ្ឍន៍ ឬតាមរយៈអង្គការក្រៅរដ្ឋាភិបាលដែលបានជួលដោយដៃគូអភិវឌ្ឍន៍។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបន្តពិភាក្សាបញ្ហានេះជាមួយដៃគូអភិវឌ្ឍន៍បន្ថែមទៀត ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងមានយន្តការគ្រប់គ្រងតួលេខចំណូល-ចំណាយដោយហិរញ្ញប្បទានក្រៅប្រទេស ដែលអនុវត្តក្រៅរតនាគារជាតិ បានច្បាស់លាស់ និងត្រឹមត្រូវ ។

## ៤.៤.២ កិច្ចបញ្ជីកាបំណុលមិនទាន់ប្រមូលផ្តុំ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានតួនាទី និងភារកិច្ចដឹកនាំ និងគ្រប់គ្រងលើការប្រមូលចំណូល និងបំណុលផ្សេងៗ ដើម្បីទ្រទ្រង់ថវិកា។ នៅក្នុងឆ្នាំ១៩៩៥ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ ត្រង់មាត្រា២០ បានបញ្ជាក់ថា គណនេយ្យកររតនាគារជាតិ ដែលជាគណនេយ្យករកណ្តាលនៃរតនាគារនៅភ្នំពេញ មានលក្ខណៈសម្បត្តិជាគណនេយ្យករដើមខ្សែ។ គណនេយ្យករនេះ អនុវត្តនូវកិច្ចប្រតិបត្តិការរបស់អាណាប័កដើមខ្សែ និងប្រមូលផ្តុំ នូវរាល់កិច្ចប្រតិបត្តិការ ដែលធ្វើឡើងដោយគណនេយ្យកររតនាគារខេត្ត-ក្រុង និងគណនេយ្យករនៃអង្គភាពរដ្ឋបាល-ហិរញ្ញវត្ថុ...។ តាមការធ្វើសវនកម្មនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទពាក់ព័ន្ធមួយចំនួន ឃើញថា កិច្ចបញ្ជីកាបំណុលពុំទាន់ត្រូវបានធ្វើការកត់ត្រាតាមដានជាលក្ខណៈប្រមូលផ្តុំនៅរតនាគារជាតិនោះទេ ហើយក៏មានបន្សល់ទុកនូវបំណុលត្រូវទារមួយចំនួន ។

ដោយហេតុដូចនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវណែនាំអង្គភាពពាក់ព័ន្ធនានា បញ្ជូនរបាយការណ៍បំណុលមករតនាគារជាតិ ដើម្បីធ្វើការកត់ត្រាតាមដានអោយបានច្បាស់លាស់ និងអនុវត្តវិធានការតឹងទារអោយបានម៉ឺងម៉ាត់ ដើម្បីប្រមូលចំណូលបង់ចូលថវិការដ្ឋអោយបានគ្រប់ចំនួន និងទាន់ពេលវេលា ។

ចំពោះការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា ក្រសួងសូមឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ដោយកន្លងមក ការកត់ត្រាតាមដានបំណុល ធ្វើឡើងដាច់ដោយឡែកតាមនាយកដ្ឋានជំនាញនីមួយៗ ប៉ុន្តែនៅពេលរតនាគារជាតិធ្វើការផ្លាស់ប្តូរប្រព័ន្ធគណនេយ្យពី " ប្រព័ន្ធគណនេយ្យផ្អែកលើបេឡាសាច់ប្រាក់ " ទៅ " ប្រព័ន្ធគណនេយ្យបង្គរ " នោះបំណុលទាំងឡាយនឹងត្រូវបានធ្វើការកត់ត្រាតាមដានប្រមូលផ្តុំនៅរតនាគារជាតិទាំងអស់។ ម្យ៉ាងវិញទៀត ចំពោះបំណុលដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើងខាងលើនេះ មួយចំនួនបានទូទាត់សងរួចរាល់ហើយ រីឯបំណុលមួយចំនួនដែលពុំទាន់ទារបាន ក្រសួងកំពុងចាត់វិធានការតឹងទារ ដោយអនុវត្តនីតិវិធីផ្សេងៗជាបន្តបន្ទាប់ ។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិរំពឹងទុកថា នឹងមានកិច្ចបញ្ជីកាបំណុលប្រមូលផ្តុំច្បាស់លាស់មួយ ហើយចំពោះបំណុលដែលពុំទាន់បានទូទាត់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងអនុវត្តវិធានការតឹងទារអោយបានខ្លាំងក្លាបន្ថែមទៀត ដើម្បីបំពេញចំណូលថវិការដ្ឋ និងធ្វើការជំរះបញ្ជី ។

## ៥. សេចក្តីសន្និដ្ឋាន

ឆ្លងតាមការចង្អុលបង្ហាញនូវចំណុចមួយចំនួនខាងលើ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា អង្គភាពរងសវនកម្មទាំងឡាយនឹងខិតខំធ្វើការកែលំអថែមទៀត ដែលជាការចូលរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអោយបានកាន់តែល្អប្រសើរ ស្របតាមគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ជាមួយគ្នានេះដែរ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា សាធារណជនទាំងឡាយនឹងចូលរួមផ្តល់មតិស្ថាបនា ព្រមទាំងលើកទឹកចិត្តចំពោះការងារដែលសំរេចបានថ្មីនេះ ដែលជំរុញអោយអាជ្ញាធរសវនកម្មជាតិបន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួនសំដៅលើកកំពស់គុណភាពសវនកម្ម ដើម្បីចូលរួមចំណែកក្នុងការការពារ និងការអភិវឌ្ឍន៍ប្រទេសជាតិ ប្រកបដោយចិរភាព ។